**សុន្ទរកថាស្វាគមន៍**

**ឯកឧត្តម បណ្ឌិត សុក ស៊ីផាន់ណា**

**ប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន វបសអ-CDRI និងជា**

**ទីប្រឹក្សានៃរាជរដ្ឋាភិបាលកម្ពុជា**

ក្នុងពិធីបើក

**សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៧**

ក្រោមប្រធានបទ

**"ការឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃសម្រាប់ឧស្សាហូបនីយកម្ម កំណើន និងការអភិវឌ្ឍន៍ ក្នុងសម័យឌីជីតាល់"**

**ថ្ងៃទី២ ខែមីនា ឆ្នាំ២០១៧**

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត**
- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា អស់លោក លោកស្រី ជាទីគោរពរាប់អាន!**

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយ សូមសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅបំផុតជូនដល់ **សម្តេច** ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ចំពោះការអញ្ជើញមកចូលរួមក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៧ នេះ ដែល វិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal បានសហការគ្នារៀបចំឡើង។ ក្នុងឱកាសដ៏វិសេសវិសាលនេះ

យើងខ្ញុំសូមសម្តែងនូវកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅបំផុតជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងបានផ្តល់នូវការជួយគាំទ្រជារៀងរហូតមក ដល់ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំ ព្រមទាំងផ្តល់តម្លៃដល់ការងារស្រាវជ្រាវឯករាជ្យផ្នែកគោលនយោបាយអភិវឌ្ឍន៍របស់វិទ្យាស្ថានយើងខ្ញុំ ដោយអញ្ជើញចូលរួមជាអធិបតី និងថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទ។ យើងខ្ញុំក៏សូមអរគុណជាពន្លឹកផងដែរដល់ ធនាគារ ANZ Royal ដែលមានការតាំងចិត្តខ្ពស់ចូលរួមសហការរៀបចំសន្និសីទចក្ខុវិស័យជាបន្តបន្ទាប់ ហើយក្នុងនេះ យើងខ្ញុំសូមអរគុណជាពិសេស ដល់ បណ្ឌិត Leonie Lethbridge អគ្គនាយក នៃធនាគារ ANZ Royal ។

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី១១ នៅឆ្នាំ២០១៧ នេះ វិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal បានសហការគ្នារៀបចំឡើងក្រោមប្រធានបទ "**ការឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃសម្រាប់ឧស្សាហូបនីយកម្ម កំណើន និងការអភិវឌ្ឍន៍ ក្នុងសម័យឌីជីតាល់**"។ ជាថ្មីម្តងទៀត សន្និសីទប្រចាំឆ្នាំនេះ បានអញ្ជើញថ្នាក់ដឹកនាំពីគ្រប់វិស័យមកជួបជុំគ្នាដើម្បី ពិនិត្យពីសមិទ្ធផលដែលកម្ពុជាសម្រេចបាន ធ្វើការផ្លាស់ប្តូរមតិយោបល់គ្នា និងពិភាក្សាពីយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍ និងការរីកចម្រើននៅប្រទេសកម្ពុជាទៅអនាគត ព្រមទាំង ផ្តល់ជាមតិយោបល់ផ្នែកគោលនយោបាយសម្រាប់ការធ្វើសកម្មភាព។

សន្និសីទចក្ខុវិស័យនៅឆ្នាំនេះ ផ្តោតលើបញ្ហាសំខាន់ៗដែលកំណត់មាគ៌ានៃការធ្វើឧស្សាហូបនីយកម្ម និងសម្រេចបានកំណើន ដើម្បីឲ្យប្រទេសកម្ពុជាមានអនាគតរុងរឿង។ ក្នុងឱកាសដ៏ប្រសើរនេះ យើងខ្ញុំសង្ឃឹមថា នឹងបានទទួលដោយផ្ទាល់ពី **សម្តេចនាយករដ្ឋមន្ត្រី** នូវ ចក្ខុវិស័យលើបញ្ហាទាំងឡាយដូចខាងលើ។

- **សម្តេចនាយករដ្ឋមន្ត្រី**
- **ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា អស់លោក លោកស្រី**

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៧ នេះ មានទិសស្លោក "**ការពន្លឿនឧត្តមភាពសេដ្ឋកិច្ចរបស់កម្ពុជា**" ដែលបញ្ជាក់ច្បាស់នូវការពិតជាក់ស្តែងថា ជោគជ័យនៃការអភិវឌ្ឍ និងរីកចម្រើនសម្រាប់ទាំងអស់គ្នានៅប្រទេសកម្ពុជាទៅអនាគត គឺអាស្រ័យលើ សមត្ថភាពជ្រៀតចូល និងឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃ ដោយផ្អែកលើ ឧត្តមភាពសេដ្ឋកិច្ច និងកម្រិតអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចនៅកម្ពុជា។ ជោគជ័យនេះក៏អាស្រ័យលើ កិច្ចសហការ ការប្តេជ្ញាចិត្ត និងភាពឧស្សាហ៍ព្យាយាម របស់អ្នកចូលរួមក្នុសន្និសីទនេះ ដើម្បីធ្វើការជាមួយគ្នាឈានទៅចាប់យកឱកាសល្អ និងដោះស្រាយបញ្ហាផ្សេងៗដែលកម្ពុជាកំពុងប្រឈមមុខ។

នាព្រឹកនេះ យើងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត ដោយ **សម្តេចនាយករដ្ឋមន្ត្រី** អញ្ជើញមកចូលរួមជាអធិបតី និងផ្តល់នូវមតិណែនាំបំផុសគំនិត និងផ្តល់ជាបរិការណ៍សម្រាប់កិច្ចពិភាក្សារបស់អង្គសន្និសីទ។ តាងនាមឲ្យ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និង ធនាគារ ANZ Royal ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត សូមគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងសុន្ទរកថាគន្លឹះ បើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៧ និងផ្តល់មតិណែនាំដល់អង្គសន្និសីទ។

សូមអរគុណ!